ប្រការ ៤ ៖ សមាជិក របស់គណៈកម្មការ ត្រូវអញ្ជើញចូលរួមប្រជុំតាមសំណើរបស់ប្រធាន ឬ អនុប្រធានគណៈកម្មការនេះ ។

ប្រការ ៥ ៖ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងវប្បធម៌និង វិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ គណៈកម្មាធិការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ អន្តរជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួងស្ថាប័នពាក់ព័ន្ធ និង ឯកឧត្តម អស់លោក ដែលមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេច អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
**ហ៊ុន សែន**

***

រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០០

## សេចក្តីសម្រេចលេខ ៤៣ សសរ
## ស្តីពីការតែងតាំងបេសកជនរបស់នាយករដ្ឋមន្ត្រី
## នៃរាជរដ្ឋាភិបាលកម្ពុជា

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់អភិបាលខេត្តកោះកុង លេខ ៧៥៦ អកក ចុះថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ ២០០០

### សម្រេច

ប្រការ ១ ៖ តែងតាំងលោកឧកញ៉ា លី យ៉ុងផាត់ ជាបេសកជនរបស់សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ទទួលបន្ទុក ការងារអភិវឌ្ឍន៍ ខេត្តកោះកុង ។

ប្រការ ២ : លោកឧកញ៉ា លី យ៉ុងផាត់ ត្រូវអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

***

រាជធានីភ្នំពេញ, ថ្ងៃទី ២៣ នៃ មិថុនា ឆ្នាំ ២០០០

## សេចក្តីសំរេចលេខ ៤៤ សសរ

## ស្តីពីការបង្កើតគណកម្មការដោះស្រាយបញ្ហាបាតុភាពព្រំដែន កម្ពុជា-ថៃតំបន់អូរជ្រៅ ខេត្តបន្ទាយមានជ័យ

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញសេចក្តីសំរេចលេខ ៤៧ សសរ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតគណកម្មការដោះស្រាយបាតុភាពបញ្ហាដីធ្លី នៅតាមបណ្តាខេត្ត - ក្រុង ទូទាំងប្រទេស
- យោងតាមស្មារតីនៃកិច្ចពិភាក្សា នាថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ ២០០០ រវាងនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងថៃ

### សំរេច

ប្រការ ១ : បង្កើតគណកម្មការដោះស្រាយបញ្ហាបាតុភាពព្រំដែនកម្ពុជា- ថៃ តំបន់អូរជ្រៅ ខេត្តបន្ទាយមានជ័យ ដែលមានសមាសភាពដូចខាងក្រោម :

១-ឯកឧត្តម ជុំ ភារណាល់ ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី ជាប្រធាន

២-ឧត្តមសេនីយ៍ទោ សឹទ្ធ ឌី មេបញ្ជាការរងកងទ័ពជើងគោក ជាអនុប្រធាន

៣-ឯកឧត្តម ឡុង វិសាលោ អនុរដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ជាអនុប្រធាន

៤-ឯកឧត្តម ថាច់ ឃន អភិបាលខេត្តបន្ទាយមានជ័យ ជាសមាជិក

៥-លោក លឹម ទ៊ាន់ អគ្គនាយករងក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ជាសមាជិក

៦-លោក ឃួន សាវ៉ាន តំណាងអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ជាសមាជិក